# ការផ្លាស់ប្តូរចំពោះការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមអេឡិចត្រូនិច (EVV) ចាប់ផ្តើមអនុវត្តនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2023 – អ្នកផ្តល់សេវាដែលមិនរស់នៅជាមួយ តារាងព័ត៌មានស្តីអំពីវិបផតថលសេវាកម្មអេឡិចត្រូនិច (ESP)

**របៀបចុះឈ្មោះនៅក្នុង ESP:**

1. ចូលទៅកាន់គេហទំព័រសំរាប់ ESP នៅ: Electronic Services Portal ។
2. ជ្រើសរើស "ចុះឈ្មោះនៅទីនេះ" ឈ្មោះហើយធ្វើតាមជំហាននីតិវិធានការ។
3. បញ្ចូលឈ្មោះរបស់អ្នក ខែថ្ងៃឆ្នាំកំណើត លេខកូដ 9-ខ្ទង់របស់អ្នកផ្តល់សេវា និងលេខកូដ 4-ខ្ទង់នៃលេខសុវត្ថិភាពសង្គមរបស់អ្នក។
4. បង្កើតឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់អ្នក ហើយបញ្ចូលអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក។

**ឈ្មោះអ្នកប្រើប្រាស់: ______________________________ ពាក្យសម្ងាត់:______________________________**

**ប្រសិនបើអ្នកបានចុះឈ្មោះចូលទៅក្នុង ESP រួចហើយ អ្នកមិនចាំបាច់ចុះឈ្មោះម្តងទៀតទេ។**

**សំរាប់ទិដ្ឋភាពទូទៅនៃទីតាំង EVV សំរាប់ការពិនិត្យចូល/ការពិនិត្យចេញ នៃកម្មវិធីចល័តសំរាប់ EVV និង ESP សម្រាប់អ្នកផ្តល់សេវាដែលមិនរស់នៅជាមួយ សូមចូលទៅគេហទំព័រខាងក្រោម៖**
**https://www.cdss.ca.gov/inforesources/cdss-programs/ihss/evvhelp**

**របៀបពិនិត្យចូលជាមួយ ESP សំរាប់អ្នកផ្តល់សេវាដែលមិនរស់នៅជាមួយ៖**

1. ឡុគចូល Log in  ទៅក្នុង **ESP** ដោយប្រើឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់អ្នក។
2. ជ្រើសរើសយកប៊ូតុង **ការពិនិត្យចូល/ពិនិត្យចេញ** នៅខ្សែដំណរទំព័រដើមវិញ
3. ជ្រើសរើសយកប៊ូតុង **ការពិនិត្យចូល**
4. ជ្រើសរើសយកប៊ូតុង **បើក** ដើម្បីបើកទីតាំងរបស់អ្នក
5. ជ្រើសរើសយកប៊ូតុង **អនុញ្ញាត** នៅលើអេក្រង់ដែលលេចឡើង តូចពណ៌ស
6. ជ្រើសរើស **អ្នកទទួលជំនួយ** ដែលអ្នកចង់ពិនិត្យចូល
   a. ជ្រើសរើស **ទីតាំង៖** ផ្ទះ ឬ សហគមន៍
   b. ជ្រើសរើសយកប៊ូតុង **ការពិនិត្យចូល**

   **កត់ចំណាំ:** ប្រសិនបើអ្នកទទួលជំនួយត្រូវបានចុះឈ្មោះទាំងកម្មវិធី IHSS និង WPCS, ជម្រើសដើម្បីជ្រើសរើស **ប្រភេទកម្មវិធី៖** កម្មវិធី IHSS ឬកម្មវិធី WPCS នឹងបង្ហាញ។  ជ្រើសរើស **ប្រភេទកម្មវិធី៖** កម្មវិធី IHSS ឬកម្មវិធី WPCS ដើម្បីបន្ត។
7. នៅលើអេក្រង់បញ្ជាក់ការពិនិត្យចូល អ្នកនឹងជ្រើសរើស '**បាទ/ចា៎ះ**' ដើម្បីបញ្ជាក់ការពិនិត្យចូល។
8. នៅលើអេក្រង់បញ្ជាក់ការពិនិត្យចូលលើកទី 2, អ្នកនឹងមានជម្រើសដើម្បីត្រឡប់ទៅខ្សែដំណរទំព័រដើមវិញ ឬ ពិនិត្យចូលសម្រាប់អ្នកទទួលជំនួយផ្សេងទៀត។

**របៀបពិនិត្យចេញជាមួយ ESP សំរាប់អ្នកផ្តល់សេវាដែលមិនរស់នៅជាមួយ៖**

1. ឡុគចូលទៅក្នុង **ESP** ដោយប្រើឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់របស់អ្នក។
2. ជ្រើសរើសយកប៊ូតុង **ការពិនិត្យចូល/ពិនិត្យចេញ** នៅខ្សែដំណរទំព័រដើមវិញ
3. ជ្រើសរើសយកប៊ូតុង **ការពិនិត្យចេញ**
4. ជ្រើសរើស **អ្នកទទួលជំនួយ** ដែលអ្នកចង់ពិនិត្យចេញ
   a. ជ្រើសរើស **ទីតាំង៖** ផ្ទះ ឬ សហគមន៍
   b. ជ្រើសរើសយកប៊ូតុង **ការពិនិត្យចេញ**

   **កត់ចំណាំ:** ប្រសិនបើអ្នកទទួលជំនួយត្រូវបានចុះឈ្មោះទាំងកម្មវិធី IHSS និង WPCS, ជម្រើសដើម្បីជ្រើសរើស **ប្រភេទកម្មវិធី៖** កម្មវិធី IHSS ឬកម្មវិធី WPCS នឹងបង្ហាញ។  ជ្រើសរើស **ប្រភេទកម្មវិធី៖** កម្មវិធី IHSS ឬកម្មវិធី WPCS ដើម្បីបន្ត។
5. បញ្ចូល **ម៉ោង** និង **នាទី** ដែលបានធ្វើការនៅថ្ងៃនោះ (តាមជម្រើស អាចត្រូវបានបញ្ចូលនៅពេលក្រោយ)
6. ជ្រើសរើសយកប៊ូតុង **ការពិនិត្យចេញ**
7. នៅលើអេក្រង់បញ្ជាក់ការពិនិត្យចេញ អ្នកនឹងជ្រើសរើស '**បាទ/ចា៎ះ**' ដើម្បីបញ្ជាក់ការពិនិត្យចេញ។
8. នៅលើអេក្រង់បញ្ជាក់ការពិនិត្យចេញលើកទី 2, អ្នកនឹងមានជម្រើសដើម្បីត្រឡប់ទៅកាន់ទំព័រចូលដំបូងវិញ ឬ ពិនិត្យចេញសម្រាប់អ្នកទទួលជំនួយផ្សេងទៀត។

**សំរាប់ទិដ្ឋភាពទូទៅនៃទីតាំង EVV សំរាប់ការពិនិត្យចូល/ការពិនិត្យចេញ ដោយប្រើ ESP សំរាប់អ្នកផ្តល់សេវាដែលមិនរស់នៅជាមួយ សូមចូលទៅគេហទំព័រ: https://www.cdss.ca.gov/inforesources/cdss-programs/ihss/evvhelp**




